
Kids of Destiny®
Reaching the Next Generation
www.kidsofdestiny.org

## 2.01 ព្រះយេស៊ូវជួបការល្បួង

តើអ្នកធ្លាប់ជួបការល្បួងហើយឬនៅ? តើអ្នកដឹងថាការ «ល្បួង» មានន័យដូចម្តេចទេ? តើអ្នកធ្លាប់ចង់ធ្វើអ្វីដែលអ្នកមិនគួរធ្វើទេ? ប៉ុន្តែអ្នកពិតជាចង់ធ្វើមែនទេ? នោះហើយជាការ «ល្បួង»។ ព្រះយេស៊ូវក៏ធ្លាប់ជួបការល្បួងដែរ។ នៅពេលដែលព្រះយេស៊ូវ ទ្រង់ត្រូវចាប់ផ្តើមការងារដែលព្រះបានចាត់ឲ្យទ្រង់ធ្វើ។ ព្រះយេស៊ូវទ្រង់បានទទួលបុណ្យជ្រមុជទឹកពីលោកយ៉ូហាន។ ព្រះវិញ្ញាណបរិសុទ្ធក៏បានយាងចុះមកឯព្រះយេស៊ូវពីឋានសួគ៌ ដូច្នេះទ្រង់នឹងមានអារម្មណ៍ នៅប្រកបជិតស្និទ្ធនឹងព្រះគ្រប់ពេលវេលា។ រឿងបន្ទាប់ដែលបានកើតឡើងនៅក្នុងជីវិតរបស់ព្រះយេស៊ូវ គឺជាពេលវេលាដែលទ្រង់ត្រូវជួបនឹងការល្បួង។

អារក្សជាអ្នកនៅពីក្រោយបញ្ហាទាំងអស់ ដែលកើតឡើងនៅលើផែនដី។ ព្រះទ្រង់ជាអ្វីៗដែលល្អបំផុត។ អារក្សគឺជាអ្វីគ្រប់យ៉ាងដែលអាក្រក់។ អារក្សគឺជាសត្រូវរបស់ព្រះ។ អារក្សបានសម្រេចចិត្តល្បួងព្រះយេស៊ូវ។ ព្រះវិញ្ញាណបរិសុទ្ធបាននាំព្រះយេស៊ូវទៅទីរហោស្ថាន។ អារក្សបានល្បួងទ្រង់អស់រយៈពេលសែសិបថ្ងៃ ទ្រង់មិនបានសោយអ្វីទាំងអស់ នៅពេលនោះព្រះយេស៊ូវទ្រង់ក៏ឃ្លាន។ អារក្សទូលទៅព្រះអង្គថា៖ «ប្រសិនបើអ្នកពិតជាព្រះរាជបុត្រារបស់ព្រះមែន ចូរធ្វើឲ្យដុំថ្មនេះត្រឡប់ទៅជានំប៉័ងទៅ»។ ព្រះយេស៊ូវទ្រង់មានបន្ទូលទៅអារក្សថា «ព្រះគម្ពីរបានចែងថាយើងមិនមែនរស់ដោយសារតែនំប៉័ងប៉ុណ្ណោះទេគឺរស់ដោយសារគ្រប់ទាំងព្រះបន្ទូលដែលពីព្រះឱស្ឋព្រះមកដែរ»។

បន្ទាប់មក អារក្សបាននាំព្រះយេស៊ូវឡើងទៅលើកំពូលភ្នំ។ វាបានទូលទ្រង់ថា "ខ្ញុំនឹងឲ្យអំណាច និងសិរីល្អនៃនគរទាំងនេះដល់អ្នក ដ្បិតបានប្រគល់មកខ្ញុំហើយ ខ្ញុំនឹងឲ្យដល់អ្នកណាស្រេចនឹងចិត្តខ្ញុំ។ ដូច្នេះ បើអ្នកក្រាបថ្វាយបង្គំខ្ញុំ នោះទាំងអស់ នឹងបានជារបស់អ្នក»។ ព្រះយេស៊ូវខឹងនឹងអារក្ស។ ទ្រង់មានបន្ទូលថា "សាតាំងអើយ ចូរថយទៅក្រោយអញទៅ! ដ្បិតមានសេចក្តីចែងទុកមកថា «ត្រូវឲ្យឯងថ្វាយបង្គំដល់ព្រះអម្ចាស់ ជាព្រះនៃឯង ហើយត្រូវគោរពដល់ទ្រង់តែ១ព្រះអង្គប៉ុណ្ណោះ» អារក្សបានព្យាយាមរឿងមួយទៀត។

វាបាននាំព្រះយេស៊ូវទៅក្រុងយេរូសាឡិម។ នៅទីនោះវាបានយកព្រះយេស៊ូវទៅកំពូលនៃព្រះវិហារ ហើយនិយាយថា "បើអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរទំលាក់ខ្លួនពីនេះទៅក្រោមចុះ ដ្បិតមានសេចក្តីចែងទុកមកថា «ទ្រង់នឹងបង្គាប់ពួកទេវតាទ្រង់ ពីដំណើរអ្នកឲ្យថែរក្សាអ្នក ទេវតានោះនឹងទ្រអ្នកដោយដៃក្រែងជើងអ្នកទង្គិចនឹងថ្ម»។ ព្រះយេស៊ូវមានព្រះបន្ទូលទៅវាថា «កុំឲ្យឯងល្បួងព្រះអម្ចាស់ជាព្រះនៃឯងឡើយ»។ (ឈ្មោះមួយទៀតសម្រាប់ព្រះយេស៊ូវគឺ "ព្រះអម្ចាស់")។

បន្ទាបពីនោះទៅអារក្សក៏បានចាកចេញពីព្រះយេស៊ូវទៅ។ វាបានសម្រេចចិត្តមិនល្បួងព្រះយេស៊ូវទៀតទេនៅថ្ងៃនោះ។ វានឹងល្បួងទ្រង់ម្តងទៀតនៅថ្ងៃណាមួយ។ មានភាពខុសគ្នាខ្លាំងរវាងព្រះយេស៊ូវនិងមនុស្សធម្មតា។ ដោយសារព្រះយេស៊ូវ ជាព្រះរាជបុត្រារបស់ព្រះ ទ្រង់មិនដែលមិនស្តាប់បង្គាប់ព្រះឡើយ។ ពេលខ្លះវាក៏ពិបាកណាស់ ពេលខ្លះទៀតព្រះយេស៊ូវត្រូវបានល្បួងជាមួយនឹងអ្វីដែលទ្រង់ពិតជាចង់ធ្វើ ប៉ុន្តែទ្រង់នៅតែគោរពតាមព្រះបិតា។ តើមានអ្វីកើតឡើងពេលយើងជួបការល្បួង?

គិតអំពីពេលវេលាដែលអ្នកពិតជា មិនចង់ស្តាប់បង្គាប់ឪពុកម្តាយ ឬតាយាយរបស់អ្នកទេ។ ពួកគេបានប្រាប់អ្នកឱ្យធ្វើអ្វីមួយ ប៉ុន្តែអ្នកមិនបានធ្វើវាទេ ឬពួកគេបានប្រាប់អ្នកកុំឲ្យធ្វើអ្វីមួយ ហើយអ្នកបានធ្វើវា។ នៅពេលយើងរៀនទុកចិត្តលើព្រះយេស៊ូវ ទ្រង់ជួយយើងឲ្យស្តាប់បង្គាប់ នៅពេលដែលយើងមិនចង់ស្តាប់បង្គាប់ក៏ដោយ។ អ្វីដែលយើងត្រូវធ្វើ គឺសុំជំនួយពីទ្រង់។ (**លូកា ៤**)

## 2.01 ព្រះយេស៊ូវជួបការល្បួង - សេចក្តីណែនាំសម្រាប់គ្រូបង្រៀន

### កំណត់សំគាល់

១) ព្រះយេស៊ូវត្រូវបានល្បួងមិនឲ្យស្តាប់បង្គាប់ព្រះ ដូចជាយើងត្រូវបានល្បួងដែរ។ ព្រះវិញ្ញាណបរិសុទ្ធបានដឹកនាំទ្រង់ទៅក្នុងទីរហោស្ថាន វាជាកន្លែងដែលទ្រង់ត្រូវបានអារក្សល្បួង។

២) អារក្សជាអ្នកនៅពីក្រោយបញ្ហាទាំងអស់ ដែលកើតឡើងនៅលើផែនដី។ វានៅទីនោះជាមួយព្រះយេស៊ូវ ដើម្បីល្បួងព្រះអង្គ បន្ទាប់ពីព្រះយេស៊ូវ ទ្រង់បានចំណាយពេលសែសិបថ្ងៃនៅវាលរហោស្ថាន ដោយគ្មានអាហារបរិភោគសោះ។ រឿងដំបូងដែលវាបានល្បួងព្រះយេស៊ូវ គឺដោយអាហារ។ វាបានប្រាប់ព្រះយេស៊ូវឲ្យធ្វើដុំថ្មទៅជានំបុ័ង។ ព្រះយេស៊ូវបានប្រាប់អារក្សថា យើងត្រូវរស់ដោយសារព្រះបន្ទូលរបស់ព្រះ មិនមែនតែអាហារប៉ុណ្ណោះទេ ។

៣) អារក្សក៏ប្រាប់ព្រះយេស៊ូវឲ្យថ្វាយបង្គំវា នោះអ្វីៗទាំងអស់ក្នុងលោកីយ៍នឹងត្រូវប្រគល់ជូនទ្រង់។ ព្រះយេស៊ូវមានព្រះបន្ទូលទៅអារក្ស ថា "អ្នកត្រូវថ្វាយបង្គំព្រះអម្ចាស់តែមួយប៉ុណ្ណោះ" ។

៤) បន្ទាប់មកសាតាំងបាននាំព្រះយេស៊ូវ ចូលក្រុងយេរូសាឡិមដល់កំពូលព្រះវិហារ។ វាបានប្រាប់ព្រះយេស៊ូវឲ្យលោតចុះ។ អារក្សបានប្រាប់ព្រះយេស៊ូវថា ព្រះបានមានបន្ទូលថា នឹងមានពួកទេវតាការពារទ្រង់។ ព្រះយេស៊ូវបានដេញអារក្សទៅ វាក៏ចេញទៅ។ ព្រះយេស៊ូវទ្រង់មានបន្ទូលថា "កុំល្បងលព្រះអម្ចាស់ជាព្រះរបស់អ្នកឡើយ" ។ (ឈ្មោះមួយទៀតសម្រាប់ព្រះយេស៊ូវគឺ" ព្រះអម្ចាស់") ។

៥) នៅពេលយើងរៀនជឿទុកចិត្តលើព្រះយេស៊ូវ យើងអាចទូលសូមទ្រង់ឲ្យជួយយើង នៅពេលដែលយើងត្រូវជួបការល្បួង មិនឲ្យស្តាប់បង្គាប់ដល់ព្រះ។

**សំណួរ:**

១) តើអ្នកណានៅពីក្រោយបញ្ហាទាំងអស់នៅលើផែនដី?
២) តើព្រះយេស៊ូវនៅទីរហោស្ថានប៉ុន្មានថ្ងៃ?
៣) តើអារក្សបាននិយាយអ្វីទៅព្រះយេស៊ូវនៅពេលដែលព្រះយេស៊ូវឃ្លាន? តើព្រះយេស៊ូវបានឆ្លើយយ៉ាងណា?
៤) តើអារក្សសាតាំងបានទូលទ្រង់ថាដូចម្តេច ប្រសិនបើព្រះយេស៊ូវយល់ព្រមថ្វាយបង្គំវា? តើព្រះយេស៊ូវឆ្លើយយ៉ាងដូចម្តេច?
៥) នៅពេលអារក្សចង់ឲ្យព្រះយេស៊ូវលោតពីលើព្រះវិហារ តើព្រះយេស៊ូវឆ្លើយយ៉ាងដូចម្តេច?
៦) បើយើងជួបការល្បួងមិនឲ្យស្តាប់បង្គាប់ព្រះ តើយើងអាចធ្វើអ្វី?

**ចម្លើយ:**

១) អារក្សជាអ្នកនៅពីក្រោយបញ្ហាទាំងអស់នៅលើផែនដី។
២) ព្រះយេស៊ូវគង់នៅវាលរហោស្ថានអស់រយៈពេលសែសិបថ្ងៃ។
៣) អារក្សបានប្រាប់ព្រះយេស៊ូវឲ្យធ្វើនំបុ័ងចេញពីដុំថ្ម ។ ព្រះយេស៊ូវមានបន្ទូលថា យើងត្រូវរស់ដោយសារតែព្រះបន្ទូលរបស់ព្រះ ។
៤) អារក្សបានទូលទ្រង់ថា វានឹងឲ្យពិភពលោកទាំងមូលទៅព្រះយេស៊ូវ ប្រសិនបើទ្រង់ថ្វាយបង្គំវា ព្រះយេស៊ូវតបថាឯងត្រូវថ្វាយបង្គំព្រះអម្ចាស់តែមួយព្រះអង្គគត់ ។
៥) ពេលអារក្សទូលព្រះយេស៊ូវឲ្យលោតពីលើកំពូលព្រះវិហារ ព្រះយេស៊ូវទ្រង់មានបន្ទូលថា "កុំល្បងលព្រះ អម្ចាស់ជាព្រះរបស់អ្នកឡើយ" ។
៦) បើយើងជួបការល្បួងមិនឲ្យស្តាប់បង្គាប់ព្រះ យើងអាចអធិស្ឋានសូមជំនួយពីព្រះ ។

Kids of Destiny®
Reaching the Next Generation



www.kidsofdestiny.org